– បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦

– តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ចំនួន ៥៥៥.០០០.០០០ រៀល ( ប្រាំរយហាសិបប្រាំលានរៀលគត់ ) មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) ក្នុងវង់ថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ។

**មាត្រា ២** : ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់បំពេញបន្ថែមបៀវត្សខែ ធ្នូ ឆ្នាំ ១៩៩៦ ជូនកងកំលាំងនគរបាលទូទាំងប្រទេសអោយបានគ្រប់គ្រាន់ទៅតាមរបបកំណត់ ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ ១២ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា

* * * *

**រាជរដ្ឋាភិបាល**

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាស់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២ ៩៦/០៨ ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំធ្វើការជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា
– បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
– តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ

**សំរេច**

មាត្រា ១ : បង្កើតគណៈកម្មាធិការជាតិធ្វើជំរឿនទូទៅ នូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ដែលមានសមាសភាព :

| | |
|---|---|
| ១_ឯកឧត្តមឧបនាយករដ្ឋមន្ត្រីនិងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| ៣_ឯកឧត្តមអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៥_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៦_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ៨_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |

៩_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក

១០_ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក

១១_លោកនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ លេខាធិការ

មាត្រា ២ : គណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាមានភារកិច្ច :

ក_ណែនាំនិងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធក្នុងការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

ខ_រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសធ្វើជំរឿនប្រជារាស្ត្រមួយ មានទីស្នាក់ការនៅក្រសួងផែនការ និងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សំរាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

គ_តែងតាំងមន្ត្រីអោយចូលរួមធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសធ្វើជំរឿនប្រជារាស្ត្រ ។

ឃ_ប្រជុំការងារតាមរបបប្រជុំមួយខែម្តង តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬអនុប្រធានគណៈកម្មាធិការនៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន ។

ង_ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ពីការងារប្រព្រឹត្តទៅនិងលទ្ធផលក្នុងការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

មាត្រា ៣ : គណៈកម្មាធិការជាតិជំរឿនទូទៅ នូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាជ្ញាធរដែនដីគ្រប់ថ្នាក់ រដ្ឋមន្ត្រីនៃក្រសួង និងឯកឧត្តម លោកក្នុងមាត្រា ១ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |